**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខៈ ៤៦១/២២ គ.វ.ក-១៩

ថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការបន្ថែមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២ នៅអំឡុងពេលចូលឆ្នាំប្រពៃណីជាតិខ្មែរ

យោងប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវចំនួន៣៨ខ្សែ និងហេដ្ឋារចនាសម្ព័ន្ធ រូបវន្តមួយចំនួនក្នុងក្រុងសៀមរាប គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (**គ.វ.ក-១៩**) សូមគោរពជម្រាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរ **រដ្ឋបាលរាជធានី-ខេត្តទាំង២៥** នឹងបន្ថែមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២ នៅតាមតំបន់កំសាន្តសំខាន់ៗ និងវត្តអារាម ដើម្បីសម្រួលឱ្យបងប្អូន ក្មួយៗ កម្មករ កម្មការិនី អាចទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញ បន្ថែមលើទីតាំងចាក់ វ៉ាក់សាំងកូវីដ-១៩ ដែលកំពុងបើកដំណើរការស្រាប់នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។ ដូច្នេះ **គ.វ.ក-១៩** សូមអំពាវនាវដូចតទៅៈ

- ចំពោះកុមារ យុវវ័យ កម្មករ កម្មការិនី ព្រមទាំងប្រជាពលរដ្ឋ ដែលមិនទាន់បានចាក់វ៉ាក់សាំងដូសមូលដ្ឋាន (ដូសទី១ និងដូសទី២) អាចទៅទទួលការចាក់វ៉ាក់សាំងដូសមូលដ្ឋាននៅតាមនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលកំពុងបន្តបើកចាក់ជូនរៀងរាល់ថ្ងៃ ឬអាចទៅទទួលយកការចាក់វ៉ាក់សាំងនៅតាមតំបន់កំសាន្តសំខាន់ៗ ឬវត្តអារាម ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរ។
- ចំពោះកុមារ យុវវ័យ កម្មករ កម្មការិនី ព្រមទាំងប្រជាពលរដ្ឋដែលដល់វេនចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ (មានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ឬបន្ទាប់ពីការចាក់វ៉ាក់សាំង ចនសុន ចនសុន ១ដូសរួច) អាចទៅទទួលការចាក់វ៉ាក់សាំងដូសទី៣ នៅតាមមន្ទីតពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលកំពុងបន្តបើកចាក់ជូនរៀងរាល់ថ្ងៃ ឬអាចទៅទទួលយកការចាក់វ៉ាក់សាំងនៅតាមតំបន់កំសាន្តសំខាន់ៗ ឬវត្តអារាម ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរ។
- ចំពោះប្រជាពលរដ្ឋ កម្មករ កម្មការិនី ដែលដល់វេនចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ (មានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់ វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ) អាចទៅទទួលការចាក់វ៉ាក់សាំងដូសទី៤ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលកំពុងបន្តបើកចាក់ជូនរៀងរាល់ថ្ងៃ ឬអាចទៅទទួលយកការចាក់វ៉ាក់សាំងនៅតាមតំបន់កំសាន្តសំខាន់ៗ ឬវត្តអារាម ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរ។

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនព័ត៌មាន និងផ្សព្វផ្សាយជូនសាធារណជនជ្រាបឱ្យបានទូលំទូលាយពីទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលត្រូវរៀបចំបន្ថែមនៅតាមតំបន់កំសាន្ត និងវត្តអារាម ដែលនឹងត្រូវបើកចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងអំឡុងចូលឆ្នាំប្រពៃណីខ្មែរតាមកាលបរិច្ឆេទខាងលើ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍ សំដៅទប់ស្កាត់ការឆ្លងរីករាលដាល កាត់បន្ថយអត្រាឈឺធ្ងន់ និងអត្រាស្លាប់ដែលបង្កដោយជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង ដែលកំពុងបន្តចរាចរនៅក្នុងសហគមន៍នៅឡើយ ក៏ដូចជាវីរុសបំប្លែងខ្លួនថ្មីផ្សេងៗទៀត ដែលកំពុងចរាចរយ៉ាងសកម្មនៅក្នុងប្រទេសមួយចំនួននាពេលបច្ចុប្បន្ននេះ **គ.វ.ក-១៩** សូមអញ្ជើញ កុមារ យុវវ័យ ព្រមទាំងប្រជាពលរដ្ឋ ក៏ដូចជាកម្មករ កម្មការិនី ស្ម័គ្រចិត្តទទួលយកការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ដូសទី៣ ឬដូសជំរុញរួច ឬដូសទី៤ ឱ្យបានគ្រប់គ្នានៅពេលដល់វេនចាក់។ ទន្ទឹមគ្នានេះដែរ **គ.វ.ក-១៩** សូមអញ្ជើញស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅកូនដោយទឹកដោះ អ្នកមានជំងឺប្រចាំកាយដែលមានការព្យាបាលបានហ្នឹងន និងអ្នកជាសះស្បើយពីជំងឺកូវីដ-១៩ ដែលមានគម្លាត៤ខែបន្ទាប់ជាសះស្បើយ ទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់គ្នា ទាំងដូសមូលដ្ឋាន ដូសទី៣ ឬដូសជំរុញ និងដូសទី៤ នៅតាមទីតាំងដូចបានជម្រាបជូនខាងលើ។

**គ.វ.ក-១៩** សូមគោរពជម្រាបជូនសាធារណជនបានជ្រាបផងដែរថា តាមការសិក្សាស្រាវជ្រាវរកឃើញថាភាពស៊ាំសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុសកូវីដ-១៩ របស់បុគ្គលដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ មានការធ្លាក់ចុះជាបន្តបន្ទាប់ បន្ទាប់ពីបានចាក់ វ៉ាក់សាំងកូវីដ-១៩ ចាប់ពី៤ខែឡើង ដូចនេះ មានតម្រូវការចាំបាច់ក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញជាបន្តបន្ទាប់ ទាំងដូសទី៣ និងដូសទី៤ សំដៅកុំឱ្យភាពស៊ាំរបស់បុគ្គល ក៏ដូចជាភាពស៊ាំក្នុងសហគមន៍មានការធ្លាក់ចុះ ដែលអាចប្រឈមនឹងភាពធ្ងន់ធ្ងរ ឬស្លាប់បណ្តាលមកពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ឡើងវិញ។

**គ.វ.ក-១៩** សូមគោរពជម្រាបជូនផងដែរថា ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចរាល់ហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «**៣ការពារ**» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពី មួយម៉ែត្រកន្លះឡើងទៅ) និង «**៣កុំ**» ( កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករច្រើន កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា ) តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា និងរក្សានិរន្តរភាព នៃការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទ ខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ / លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៨៨៩ ០៨៥ | ០១២ ៩១៦ ០៩៩ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)**

**វេជ្ជ. ឱ្យ វណ្ណឌីន**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩